**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ១៤៩៧ បទ.

ថ្ងៃ ពុធ ១៥កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## វឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត និងការបើកការពិគ្រោះយោបល់ជាសាធារណៈ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) មានកិត្តិយសសូមជម្រាបជូនក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល បណ្តាក្រុមហ៊ុន សហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មីគ្រប់វិស័យ គ្រឹះស្ថានអប់រំស្រាវជ្រាវ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អ្នកវិជ្ជាជីវៈឌីជីថល សិស្សនិស្សិត(“ភាគីពាក់ព័ន្ធ”)ទាំងអស់ និងសាធារណជន មេត្តាជ្រាបអំពីវឌ្ឍនភាពនៃការរៀបចំ “**យុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត**” ដូចខាងក្រោម៖

បន្ទាប់ពីសិក្ខាសាលាពិនិត្យស៊ីជម្រៅនាថ្ងៃទី៧-៨ ខែមេសា ឆ្នាំ២០២៥ ក្រុមការងាររបស់ **ក.ប.ទ.** បានកែសម្រួលសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិតនិងបានផ្ញើសេចក្តីព្រាងដែលបានកែសម្រួល ជូនក្រសួង ស្ថាប័នពិនិត្យនិងផ្តល់យោបល់ ព្រមទាំងបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នជាទ្វេភាគី និងពហុភាគីសរុបចំនួន ១០លើក ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ ជាលទ្ធផលក្រសួង ស្ថាប័នជាច្រើនបានលើកមតិគាំទ្រនិងផ្តល់មតិយោបល់ល្អៗលើសេចក្តីព្រាងនេះ។ ជាជំហានបន្ទាប់ **ក.ប.ទ.** នឹងបន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល តំណាងវិស័យឯកជន គ្រឹះស្ថានអប់រំស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ក្នុងសប្តាហ៍ទី៣ ខែមិថុនា ឆ្នាំ២០២៥ ហើយនឹងរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត នៅសប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៥។

ដើម្បីប្រមូលធាតុចូលឱ្យបានកាន់តែទូលំទូលាយពីភាគីពាក់ព័ន្ធ សំដៅធ្វើឱ្យសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិតក្លាយទៅជាឯកសារថ្នាក់ជាតិដ៏ពេញលេញ **ក.ប.ទ** សូមបើកការពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥។

ដើម្បីចូលរួមផ្តល់យោបល់ សូមទាញយកសេចក្តីព្រាងយុទ្ធសាស្ត្រនេះ ឯកសារទស្សនាទាន និងតារាងផ្តល់យោបល់តាមរយៈឃ្យូអរកូដទី១ ខាងក្រោម រួចបំពេញទម្រង់បែបបទអនឡាញនិងភ្ជាប់តារាងផ្តល់យោបល់ដែលបានបំពេញរួចនិងឯកសារភ្ជាប់ផ្សេងទៀត ប្រសិនបើមាន តាមរយៈឃ្យូអរកូដទី២ខាងក្រោម ឱ្យបានមុនថ្ងៃទី២០ ខែមិថុនា

ឆ្នាំ២០២៥ វេលាម៉ោង ១១:៥៩នាទីយប់។ ក្រុមការងាររបស់ **ក.ប.ឌ**. នឹងពិនិត្យនិងបូកសរុបមតិយោបល់ទាំងអស់ដើម្បីពិចារណាជ្រើសរើសជាធាតុចូលបន្ថែមសម្រាប់សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈអ៊ីមែល ai-governance@mptc.gov.kh ឬទូរសព្ទលេខ ០៩៦ ៦៥១ ៣០០៣។

សេចក្តីដូចមានជម្រាបជូនខាងលើ សូម ភាគីពាក់ព័ន្ធទាំងអស់និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន និងចូលរួមពិនិត្យនិងផ្តល់យោបល់តាមការគួរ។ ៚

ទាញយក
ឯកសារពាក់ព័ន្ធ៖

GO.gov.KH

អាប់ឡូដ
មតិយោបល់៖

GO.gov.KH